គណបក្ស សម រង្ស៊ី
ឆ្នាំ
SAM RAINSY PARTY
PARTI SAM RAINSY
សីលធម៌ សច្ចធម៌ យុត្តិធម៌

11 10 ២០០២
332

គណបក្ស សម រង្ស៊ី

ជំរាបជូន

លោក ព្រះរាជអាជ្ញាអមតុលាការ ក្រុងភ្នំពេញ

**កម្មវត្ថុ** ៖ ប្ដឹងនិពន្ធនាយកសារព័ត៌មានរស្មីកម្ពុជាពីបទផ្សាយព័ត៌មានមិនពិត និងបរិហារកេរ្តិ៍ ។

**យោង** ៖ -មាត្រា១០ នៃច្បាប់ ស្ដីពី របបសារព័ត៌មានដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨៩៥.០៨ ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៩៥

-មាត្រា៦៣ នៃបទបញ្ញត្តិ ស្ដីពី ច្បាប់ប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ សំរាប់អនុវត្តនៅប្រទេសកម្ពុជា ក្នុងសម័យអន្តរកាល (១៩៩២) ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជំរាបជូនលោកព្រះរាជអាជ្ញាជ្រាបថា សារព័ត៌មានរស្មីកម្ពុជា ឆ្នាំទី១០ លេខ២៨៨១ ថ្ងៃទីសុក្រ ទី១១ ខែតុលា ឆ្នាំ២០០២ បានចុះផ្សាយអត្ថបទមានចំណងជើងថា “ **មន្ត្រីមិនសប្បាយចិត្តនៅពេលបន្ទាប់ការចោទប្រកាន់លោក សម រង្ស៊ី** ” ។ ខ្លឹមសារនៃអត្ថបទនេះ បានធ្វើឲ្យប៉ះពាល់កិត្តិយសថ្នាក់ដឹកនាំគណបក្ស ព្រោះអ្នកនិពន្ធបានយកព័ត៌មានមិនពិតពីប្រភពអនាមិកមកចុះផ្សាយលើទំព័រសារព័ត៌មានរស្មីកម្ពុជា ។ ការផ្សាយព័ត៌មានមិនពិតបែបនេះ ជាចេតនាបំផ្លាញកេរ្តិ៍ឈ្មោះ កិត្តិយស និង សេចក្ដីថ្លៃថ្នូរ ថ្នាក់ដឹកនាំ និងគណបក្ស សម រង្ស៊ី ទាំងមូល ។

អាស្រ័យដូចបានជំរាបជូនខាងលើ ខ្ញុំសូមលោកព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ដល់និពន្ធនាយកសារព័ត៌មានរស្មីកម្ពុជាដាក់ជូនតុលាការធ្វើការផ្ដន្ទាទោសទៅតាមច្បាប់ ។

សូម លោកព្រះរាជអាជ្ញា ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅ អំពីខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែតុលា ឆ្នាំ២០០២

ជ. ប្រធានគណបក្ស

អគ្គលេខាធិការ

អេង ឆៃអ៊ាង

**ចំលងជូន:**

-ក្រសួងយុត្តិធម៌

-ក្រសួងព័ត៌មាន

-ស្ថានទូតនានាប្រចាំនៅកម្ពុជា

-សារព័ត៌មានជាតិ និងអន្តរជាតិ